# ជំហាននិមួយៗដែលលោកអ្នកធ្វើដើម្បីបញ្ឈប់ការស្រូបផ្សែងបារីដោយមិនដឹងខ្លួន (passivesmoking) និងការពារកូនក្មេងម្នាក់ពីគ្រឿងពុលដែលនាំឲ្យមានគ្រោះថ្នាក់

## រថយន្ត និង ផ្ទះ

## ជាកន្លែងគ្មានផ្សែងបារី

### ពត៌មានបន្ថែម

**Cabramatta Community Health Centre**
8717 4000
**The Cancer Council NSW**
131 120
**Asthma NSW**
1800 645 130
**The National Health Foundation**
1300 362 307
**SIDS and Kids NSW**
1300 308 307

បើសិនជាលោកអ្នកចង់ឈប់ជក់

សូមទាក់ទងនឹង **Quitline 131 848**

ឬនិយាយជា

មួយនឹងវេជ្ជបណ្ឌិតឬឱសថការីលោកអ្នក

មើលគេហទំព័រ:

www.smokefreezone.org.au

Car and Home: Smoke Free Zone Khmer
September 2002
[DOH-6110]

# រថយន្តនិងផ្ទះ

# ជាកន្លែងគ្មាន

# ផ្សែងបារី

## តើការស្រូបផ្សែងបារីដោយមិនដឹងខ្លួនជាអ្វី?

ការស្រូបផ្សែង៉រីដោយមិនដឹងខ្លួនគឺជាការស្រូបផ្សែងបារី ស៊ីហ្គាឬខ្សៀរបស់អ្នកដទៃ។ ផ្សែងនេះចេញមកដោយត្រង់ៗពីចុងបារីដែលឆេះព្រមគ្នានឹងផ្សែងដែលបញ្ចេញតាមដង្ហើមអ្នកដែលជក់បារី។ ផ្សែងបារីនេះមាន**សារធាតុគីមីខុសៗគ្នាប្រហែលបួនពាន់មុខដែលភាគច្រើនជាជាតិពុលឬជាតិដែលបណ្តាលឱ្យកើតជំងឺមហារីក** ហើយនាំឱ្យមានគ្រោះថ្នាក់ដល់ទារកនិងកូនក្មេងគ្រប់វ័យទាំងអស់ព្រមទាំងជនពេញវ័យផងដែរ។
ជាតិពុលពីផ្សែងបារីអាចឋិតនៅក្នុងខ្យល់ទោះបីជាគេលែងឃើញផ្សែងហើយក៏ដោយ។

ផ្សែងបារីហើរទៅដល់គ្រប់កន្លែងនៅក្នុងផ្ទះទោះបីជាគេពុំជក់នៅក្នុងបន្ទប់នោះក៏ដោយ។
ផ្សែងបារីហើរទៅដល់គ្រប់កន្លែងក្នុងរថយន្តដែរ។ គឺពុំគ្រប់គ្រាន់ទេដែលគេគ្រាន់តែបើកចំហបង្អួចរថយន្តនោះ។
**នៅពេលដែលអ្នក,ដៃគូអ្នក សមាជិកគ្រួសារ មិត្តភ័ក្តិជក់នៅត្រង់កន្លែងដែលក្មេងរស់នៅ ដកដង្ហើមនោះមានន័យថាកូនក្មេងទាំងនោះក៏ជក់ដែរ។**

## តើលោកអ្នក

មានមធ្យោបាយដែលមានប្រសិទ្ធភាពដើម្បីការពារកូនក្មេងពីផ្សែងបារីរបស់អ្នកដទៃ។

ដើម្បីឱ្យប្រាកដថាកូនក្មេងមិនបះពាល់នឹងផ្សែងបារីទេត្រូវធ្វើឱ្យ**រថយន្តនិងផ្ទះលោកអ្នកជាកន្លែងដែលគ្មានផ្សែងបារី។**

***តទៅនេះជារបៀបខ្លះដែលត្រូវចាប់ផ្តើមធ្វើនៅក្នុងរថយន្ត:***

- ដាក់វិន័យរថយន្តលោកអ្នកមិនត្រូវមានផ្សែងបារីទេសំរាប់គ្រួសារនិងមិត្តភ័ក្តិទាំងអស់។
- ទាក់ទងនឹង The Cancer Council NSW ដើម្បីបានផ្ទាស (stickers) ដើម្បីធ្វើឱ្យប្រាកដថារថយន្តលោកអ្នកជាកន្លែងដែលគ្មានផ្សែងបារី។

## ហេតុដូចម្តេចបានជាការស្រូបផ្សែងបារីដោយមិនដឹងខ្លួនមានគ្រោះថ្នាក់ដល់ក្មេង?

ទារកនិងកូនក្មេងគ្រប់វ័យទាំងអស់មានបញ្ហាសុខភាពដោយសារផ្សែងបារីរបស់អ្នកដទៃដោយហេតុថា:

- សួតវាតូចហើយទំងន់ខ្លួនរបស់វាស្រាល ដូច្នេះសារធាតុពុលនៅក្នុងផ្សែងបារីធ្វើឱ្យមានគ្រោះថ្នាក់ខ្លាំង។
- កូនក្មេងចំណាយពេលវេលាជាច្រើនជាមួយឪពុកម្តាយឬអ្នកថែរក្សាហើយបើសិនជាអ្នកទាំងនោះជក់នោះកូនក្មេងអាចប៉ះពាល់និងមានផលវិបាកអាក្រក់សំរាប់រយះពេលដ៏យូរ។
- ទារកនិងកូនក្មេងពុំអាចនឹងដើរចេញឆ្ងាយបានគ្រប់ពេលពីផ្សែងបារីរបស់អ្នកដទៃទេ។

**ផ្សែងបារីអាចហើរទៅដល់ទោះបីជាកូនក្មេងឋិតនៅពីក្រោយទ្វារដែលបិទជិតនៅពេលដែលវាគេងលក់ឬលេងក៏ដោយ។**

## អាចធ្វើដូចម្តេចបានដើម្បី

- បិតផ្លាកហាមជក់បារីនៅត្រង់ប្រដាប់គោះកំទេច៉បារីនិង dashboard
- សំអាតប្រដាប់គោះកំទេចបារីក្នុងរថយន្តហើយដកប្រដាប់អុជបារីចេញ
- ហើយសូមចាំថាការបើកបង្អួចនឹងពុំការពារកូនលោកអ្នកទេ។

***តទៅនេះជារបៀបខ្លះដែលត្រូវចាប់ផ្តើមធ្វើនៅផ្ទះ***

- ដាក់**វិន័យ-** ផ្ទះលោកអ្នកមិនត្រូវមានផ្សែងបារីទេសំរាប់គ្រួសារ និងមិត្តភក្តិទាំងអស់។
- ទាក់ទងនឹង The Cancer Council NSW ដើម្បីបានផ្លាក (stickers) និង magnets ដើម្បីធ្វើឱ្យប្រាកដថារថយន្តលោកអ្នកជាកន្លែងដែលគ្មានផ្សែងបារី។
- បិតផ្លាក magnets ឬ stickers ដែលមានពាក្យ កន្លែងគ្មានផ្សែងបារីនៅលើទូរទឹកកកក្នុងផ្ទះបាយនិងកន្លែងសំខាន់នៅក្នុងផ្ទះ។

## តើការស្រូបផ្សែងបារីដោយមិនដឹងខ្លួនមានគ្រោះថ្នាក់ដល់កូនក្មេងដូម្តេចដែរ?

ទារកនិងក្មេងគ្របខ្ញុំវ័យទាំងអស់ដែលស្រូបយកផ្សែងបារីពីជនដទៃអាចៈ

- កើតអំបៅអំបែក
- ការរលាកក្នុងត្រចៀក ច្រមុះ ឬសួត រលាកដើមបំពង់កនិងការដកដង្ហើមឮថ៊ឺតៗ
- កើតជំងឺហឺតដែលរ៉ាំរ៉ៃ
- កើតជម្ងឺហើមសួតនិងរលាកទងសួត
    - អាចមានគ្រោះថ្នាក់នឹងជម្ងឺដែលធ្វើឱ្យទារកស្លាប់ភ្លាម (SIDS)

**កូនក្មេងអាចមានបញ្ហាសុខភាពនៅពេលដែលវាប៉ះពាល់នឹងផ្សែងបារីរបស់ជនដទៃ។**

## ការពារសុខភាពកុមារម្នាក់?

- ដកយកប្រដាប់គោះកំទេចបារីចេញពីក្នុងផ្ទះលោកអ្នក
- សុំឱ្យនរណាដែលចង់ជក់ឱ្យចេញទៅក្រៅ- គឺពុំគ្រប់គ្រាន់ទេដោយគ្រាន់តែបើកទ្វារឬបង្អួចនោះ
- ជ្រើសរើសកន្លែងជក់បារីមួយនៅក្រៅផ្ទះលោកអ្នក ហើយផ្តល់ប្រដាប់គោះកំទេចបារីនិងត្រូវដាក់ឱ្យឆ្ងាយពីដៃកូនក្មេងតូចៗ
- បើសិនជាលោកអ្នកចូលរួមនៅកន្លែងសាធារណៈជិតអ្នកជក់បារីសូមប្រាប់គេដោយគួរសមឱ្យគេចេញឆ្ងាយពីក្មេងឬក៏យកក្មេងទាំងនោះ ទៅកន្លែងថ្មីដែលគ្មានផ្សែង៉រី។
- ជួយកូនក្មេងឱ្យគ្នាមានសុខភាពល្អបំផុតដែលអាចធ្វើទៅបានដោយទុកឱ្យវានៅឱ្យឆ្ងាយពីផ្សែងបារី។